ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២០ លេខ៦៩ ត្រីមាសទី០៣ ឆ្នាំ២០២០

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

សារធាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា សារាចរ ប្រកាស

ក

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២៧-៨-២០២០	-ព្រះរាជក្រឹត្យ នស/រកត/០៨២០/៨៩៩ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ទោ ជាកិច្ចបច្ឆាមរណៈ ចំពោះឧត្តមសេនីយ៍ត្រី **ឯក សុវណ្ណា** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ដែលបានទទួលមរណភាព	៨៤៤៥
២៧-៨-២០២០	-ព្រះរាជក្រឹត្យ នស/រកត/០៨២០/៩០០ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រី ដល់នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ៣៧ រូប	៨៤៤៦
២៧-៨-២០២០	-ព្រះរាជក្រឹត្យ នស/រកត/០៨២០/៩០១ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ឯក ដល់ឧត្តមសេនីយ៍ទោ **ឈន ប្រាសាទ** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ	៨៤៤៨
២៧-៨-២០២០	-ព្រះរាជក្រឹត្យ នស/រកត/០៨២០/៩០២ ស្តីពី ការផ្តល់គោរមងារលោក **តេ ពិសិដ្ឋ** ជាឧកញ៉ា	៨៤៤៩
២៧-៨-២០២០	-ព្រះរាជក្រឹត្យ នស/រកត/០៨២០/៩០៣ ស្តីពី ការបញ្ចប់មុខតំណែងឯកឧត្តម **រឿន រិទ្ធីវ័ន្ត** ពីអនុរដ្ឋលេខាធិការ និងតែងតាំងមុខតំណែងឯកឧត្តម ជាអគ្គនាយក នៃអគ្គនាយកដ្ឋាន កិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	៨៤៥០
២៧-៨-២០២០	-ព្រះរាជក្រឹត្យ នស/រកត/០៨២០/៩០៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសមុនីសារភ័ណ្ឌ តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម អស់លោក និងកងកម្លាំងប្រដាប់អាវុធ ចំនួន ១៨ រូប	៨៤៥១
២៧-៨-២០២០	-ព្រះរាជក្រឹត្យ នស/រកត/០៨២០/៩០៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ចំពោះ កងកម្លាំងប្រដាប់អាវុធ ចំនួន ១៥ រូប	៨៤៥៣
២៧-៨-២០២០	-ព្រះរាជក្រឹត្យ នស/រកត/០៨២០/៩០៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម អស់លោក និងលោកស្រី ចំនួន ៤១ រូប	៨៤៥៥
២៧-៨-២០២០	-ព្រះរាជក្រឹត្យ នស/រកត/០៨២០/៩០៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ឈិន សីសុខ** **(CHEN SHISONG)** ជនជាតិចិន សញ្ជាតិចិន	៨៤៥៧

២៧-៨-២០២០	-ព្រះរាជក្រឹត្យ នស/រកត/០៨២០/៩០៨ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **លី ថៃសាន្ត** (**LEE, TAI-SHAN**) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់	៨៤៥៨
២៧-៨-២០២០	-ព្រះរាជក្រឹត្យ នស/រកត/០៨២០/៩០៩ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **លី ហ្គូឌឺ** **(LEE, KUO-TZU)** ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់	៨៤៥៩
២៧-៨-២០២០	-ព្រះរាជក្រឹត្យ នស/រកត/០៨២០/៩១០ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ស៊ូ យ៉ុងឈាំង** **(SU, YONGQIANG)** ជនជាតិចិន សញ្ជាតិចិន ដោយប្តូរឈ្មោះជា **ស៊ូ យ៉ុង** **(SU YONG)**	៨៤៦០
២៧-៨-២០២០	-ព្រះរាជក្រឹត្យ នស/រកត/០៨២០/៩១១ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ហ័ង ជឺងភីង** **(HUANG, JUNPING)** ជនជាតិចិន សញ្ជាតិចិន	៨៤៦១
២៧-៨-២០២០	-ព្រះរាជក្រឹត្យ នស/រកត/០៨២០/៩១២ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ឈិន យ៉ាងវ៉ៃ** **(CHEN, YANGWEI)** ជនជាតិចិន សញ្ជាតិចិន	៨៤៦២
២៧-៨-២០២០	-ព្រះរាជក្រឹត្យ នស/រកត/០៨២០/៩១៣ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **ហេ ប៉ាន** **(HE, PAN)** ជនជាតិចិន សញ្ជាតិចិន ដោយប្តូរឈ្មោះជា **ប៉ាយ ហោអ៊ូ** **(BAI HAOYU)**	៨៤៦៣
២៧-៨-២០២០	-ព្រះរាជក្រឹត្យ នស/រកត/០៨២០/៩១៤ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោកស្រី **វ៉ាងកាម៉ុនមីត ភីមថាវ៉ាន់** **(WANGAMONMIT PIMPAWAN)** ជនជាតិថៃ សញ្ជាតិថៃ ដោយប្តូរឈ្មោះជា **ណាំ លីណេ** **(NAM LYNE)**	៨៤៦៤
២៨-៨-២០២០	-ព្រះរាជក្រឹត្យ នស/រកត/០៨២០/៩១៥ ស្តីពី ការតម្លើងឋានន្តរស័ក្តិដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ និងនាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ចំនួន ២០ រូប	៨៤៦៥
២៨-៨-២០២០	-ព្រះរាជក្រឹត្យ នស/រកត/០៨២០/៩១៦ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ឈិន ជាងប៉ូ** **(CHEN JIANGPO)** ជនជាតិចិន សញ្ជាតិចិន	៨៤៦៧
២៨-៨-២០២០	-ព្រះរាជក្រឹត្យ នស/រកត/០៨២០/៩១៧ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ឈិន ជានហ៊ុយ** **(CHEN JIANHUI)** ជនជាតិចិន សញ្ជាតិចិន	៨៤៦៨
២៨-៨-២០២០	-ព្រះរាជក្រឹត្យ នស/រកត/០៨២០/៩១៨ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្ម ដល់លោក **យ៉ាវ ជាអ៊ី** **(YAO, JIAYI)** ជនជាតិចិន សញ្ជាតិចិន	៨៤៦៩

២៨-៨-២០២០	-ព្រះរាជក្រឹត្យ នស/រកត/០៨២០/៩១៩ ស្តីពី ការផ្តល់គោរមងារលោក **ហោ សំណាង** ជា ឧកញ៉ា	៨៤៧០

II~រាជរដ្ឋាភិបាល

អនុក្រឹត្យ

១១-៨-២០២០	-អនុក្រឹត្យលេខ ១២៤ អនក្រ.បក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃរាជបណ្ឌិត្យសភាកម្ពុជា	៨៤៧១
១៦-៧-២០២០	-អនុក្រឹត្យលេខ ៦៧៥ អនក្រ.តត ស្តីពី ការជូនមេដាយការងារ	៨៥០៧

III~ការងារបណ្តារក្រសួង

ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

៣១-១២-២០១៩	-ប្រកាសលេខ ១៤៧៦ សហវ.អថ ស្តីពី ការប្រគល់កាតព្វកិច្ចប្រមូលចំណូលគ្រឹះស្ថានសាធារណៈរដ្ឋបាល សម្រាប់ការគ្រប់គ្រងឆ្នាំ ២០២០	(*តទៅ រាជកិច្ចលេខ៧០*) ៨៥៥៨

ព្រះរាជក្រឹត្យ

យើង

ន៧/រកត/០៨២០/៨៩៩

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជ៦ការជរដ្ឋបូរណសន្តិ សុតមន្តណ សិរីវិបុណ
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បន្តាប់

មាត្រា ១ : តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ទោ** ជាកិច្ចបច្ចាមរណៈចំពោះឧត្តមសេនីយ៍ត្រី **៦ក សុវណ្ណា** អត្តលេខ ០១២៦០ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ដែលបានទទួលមរណភាព ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ឆ.ស.២០០៨.៩២១

ន សីហមុនី

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០២០

បានបម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/០៨២០/ ៩០០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សម្ងានតូមិជាតិសាសនា រក្ខិតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិត្រាធរាមហាក្សត្រ
ខេមរាជនា សម្តេហោតាស អង្គុជឯករាជរដ្ឋបូរណាសន្តិ សុតមច្ចលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ត្រី** ជាន់នាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ :

១.	វរសេនីយ៍ឯក	**ប៉ែន**	**ផល្លី**	អគ្គលេខ ០២០៧៩
២.	វរសេនីយ៍ឯក	**ម៉ៅ**	**សាន់**	អគ្គលេខ ០២៨៦៩
៣.	វរសេនីយ៍ឯក	**គង់**	**គីមស្រ៊ុន**	អគ្គលេខ ០៣១០៦
៤.	វរសេនីយ៍ឯក	**អាស**	**ឆេន**	អគ្គលេខ ០៤៥៦៣
៥.	វរសេនីយ៍ឯក	**ប៉ែន**	**ឃុន**	អគ្គលេខ ០៤៥៧៣
៦.	វរសេនីយ៍ឯក	**ង៉ាត**	**ផល្លី**	អគ្គលេខ ០៨១២១
៧.	វរសេនីយ៍ឯក	**យស**	**គីរិទ្ធ**	អគ្គលេខ ០៨៥០៦
៨.	វរសេនីយ៍ឯក	**ព្រាហ្ម**	**ឌាសនា**	អគ្គលេខ ០៨៥២១
៩.	វរសេនីយ៍ឯក	**ពុត**	**កឃ**	អគ្គលេខ ០៨៧៩៥
១០.	វរសេនីយ៍ឯក	**ស៊ុំ**	**សារឿន**	អគ្គលេខ ០៩០៨៨
១១.	វរសេនីយ៍ឯក	**ស៊ុម**	**សោភ័ណ្ឌ**	អគ្គលេខ ០៩៦៣៨
១២.	វរសេនីយ៍ឯក	**សន**	**គីមសួរ**	អគ្គលេខ ១០២៧៨

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

១៣.	វរសេនីយ៍ឯក	ប៊ុន	ផេង	អត្តលេខ ១០៣១៧
១៤.	វរសេនីយ៍ឯក	សោម	ឡឿន	អត្តលេខ ១០៣៧២
១៥.	វរសេនីយ៍ឯក	ង៉ាន់	រិទ្ធ	អត្តលេខ ១០៥៤៤
១៦.	វរសេនីយ៍ឯក	សៅ	សារុន	អត្តលេខ ១១១៣៥
១៧.	វរសេនីយ៍ឯក	កែវ	សាក់	អត្តលេខ ១១៣៧៣
១៨.	វរសេនីយ៍ឯក	កែវ	សុថា	អត្តលេខ ១៣៨៩៩
១៩.	វរសេនីយ៍ឯក	ប៉េង	ពិសិដ្ឋ	អត្តលេខ ១៤៤៣៦
២០.	វរសេនីយ៍ឯក	អ៊ុក	សំអៀង	អត្តលេខ ១៤៨៤១
២១.	វរសេនីយ៍ឯក	ម៉ែន	សារ៉ុម	អត្តលេខ ១៨០១២
២២.	វរសេនីយ៍ឯក	ញ្ញាន	សារឿន	អត្តលេខ ២៣៤៥០
២៣.	វរសេនីយ៍ឯក	ង្រាក់	ជុត	អត្តលេខ ២៨៦១៤
២៤.	វរសេនីយ៍ឯក	ហ៊ិន	សុខខេង	អត្តលេខ ៣០២៦៨
២៥.	វរសេនីយ៍ឯក	កឹង	ម៉ៅ	អត្តលេខ ៣០៤៩២
២៦.	វរសេនីយ៍ឯក	ម៉ែន	កល្យាណ	អត្តលេខ ៥៤១៩០
២៧.	វរសេនីយ៍ឯក	ហួន	ចាន់ថាសនា	អត្តលេខ ៥៤៩២៦
២៨.	វរសេនីយ៍ឯក	ឆាយ	សាឆុង	អត្តលេខ ៥៦០៥១
២៩.	វរសេនីយ៍ឯក	ម៉ែន	រ៉ាឡឿន	អត្តលេខ ៥៦៦១៣
៣០.	វរសេនីយ៍ឯក	ស្រ៊ាង	គីមលី	អត្តលេខ ៥៧៣៧៧
៣១.	វរសេនីយ៍ឯក	ជីវ	សេងរស់	អត្តលេខ ៥៩១១៥
៣២.	វរសេនីយ៍ឯក	តាក	សារិទ្ធ	អត្តលេខ ៥៩៨១១
៣៣.	វរសេនីយ៍ឯក	ជឹង	ឃាងលី	អត្តលេខ ៦១៩៥៥
៣៤.	វរសេនីយ៍ឯក	អេង	លីហួរ	អត្តលេខ ៦៣៧១៣
៣៥.	វរសេនីយ៍ឯក	ឆួច	ពិសិដ្ឋ	អត្តលេខ ៦៣៩៩៨
៣៦.	វរសេនីយ៍ឯក	ហោង	ណាច	អត្តលេខ ៧១២១០
៣៧.	វរសេនីយ៍ឯក	គង់	កែវ	អត្តលេខ ៧៧៨៨១ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០២០

នរោត្តម សីហមុនី

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ឧបនាយករដ្ឋមន្ត្រីប្រចាំការ

រដ្ឋមន្ត្រីទទួលបន្ទុកអគ្គិសីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ម៉ិន ឈិន

ព្រះរាជក្រឹត្យ

នស/រកត/០៨២០/៩០១

យើង

ព្រះអរុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា អ្នតឧត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ងហោតាស អង្គុជឯករាជរដ្ឋបូរណាសន្តិ សុតអគ្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ដ្ឋេធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ឯក** ជាឧត្តមសេនីយ៍ទោ **ឈន ឃ្លាសាន** អត្តលេខ ៥៣៥៣៦ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃចុះព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០២០

នរោត្តម សីហមុនី

បានបម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកអចិន្ត្រៃយ៍នៃគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសល្យបណ្ឌិត ប៊ិន ឈិន

ព្រះរាជក្រឹត្យ

ឈើច

ឆស/រកត/០៨២០/ ៩០៤

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាវជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជ៦ករាជរដ្ឋបូរណសន្តិ សុតមន្តណ សិរីវិបុណ
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

ត្រាស់បន្តាប់

ផ្តល់គោរមងារ :

លោក **គេ ពិសិដ្ឋ**

ជា

ឧកញ៉ា

៣៧៧.៤០០៨.៩៤៤

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៤៧ ខែ សីហា ឆ្នាំ ២០២០

ន សីហមុនី

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/០៨២០/ ៩០៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោតាស កម្ពុជ៦អរាជរដ្ឋបូរណសន្តិ សុតមន្តណ សិរីវិបុណ
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បន្តាប់

មាត្រា ១ : បញ្ចប់មុខតំណែងឯកឧត្តម **ទ្រឿន រិទ្ធីរ័ត្ន** ពីអនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

មាត្រា ២ : តែងតាំងមុខតំណែងឯកឧត្តម **ទ្រឿន រិទ្ធីរ័ត្ន** ជាអគ្គនាយក នៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពាក្យ.២០០៨.៩២៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០២០

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសល់បណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/០៨២០/ ៩០៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សម្ហនតូមិជាតិសាសនា រក្ខតខត្តិយា ខេមរាវជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស អម្ពុជឯករាជរដ្ឋបូរណសន្តិ សុតមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

នូវ

ក- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- ឧត្តមសេនីយ៍ត្រី	**ជាវ វិបុល**	អត្តលេខ ០៦១៣៤
២- ឯកឧត្តម	**គេង រតនា**	
៣-លោក	**សុង ប៊ុណ្ណារិទ្ធ**	
៤- លោក	**ម៉ម ច័ន្ទវណ្ណ:**	
៥- វរសេនីយ៍ឯក	**ផ្ទៀង ច័ន្ទសារ**	អត្តលេខ ០៥៤៨៣

ខ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** :

១- វរសេនីយ៍ទោ	**ហែម បូណា**	អត្តលេខ ៥៩៦៩៥
២- វរសេនីយ៍ទោ	**ជឿន សមភ័ណ្ឌ**	អត្តលេខ ៣៧៥៩១
៣- វរសេនីយ៍ទោ	**រស់ សុគន្ធី**	អត្តលេខ ៦២១០៧
៤- វរសេនីយ៍ត្រី	**ប៊ុន ប្រុស**	អត្តលេខ ១៧៥៧៦

គ- គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** :

១- អនុសេនីយ៍ឯក	**ម៉ា ប៉ាន់សម**	អត្តលេខ ៦៥៣៤៤
២- អនុសេនីយ៍ឯក	**ទូ គារិន**	អត្តលេខ ៦៦៨៩០
៣- អនុសេនីយ៍ឯក	**ឈុន ណយ**	អត្តលេខ ៦៦៥២៨

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

យ- ត្រឿងឥស្សរិយយស **មុនីសារាឥណ្ឌា** ថ្នាក់ **សេនា** :

១- អនុសេនីយ៍ទោ	**ជួន គេន:**	អត្តលេខ ៨៤២៧៨
២- អនុសេនីយ៍ទោ	**អោក សីហា**	អត្តលេខ ៨១០៦៤
៣- អនុសេនីយ៍ត្រី	**ជាម ម៊ីលី**	អត្តលេខ ៨៦៣០២
៤- អនុសេនីយ៍ត្រី	**ឆែ ជាវ៉ា**	អត្តលេខ ៨៥៦២១
៥- អនុសេនីយ៍ត្រី	**ចេក ចំណាប់**	អត្តលេខ ៨៧៥៧៩
៦- ព្រិន្ធបាលទោ	**ខាត់ មិថុនា**	អត្តលេខ ៩០១៥៣

លរ.២០០៨.៩៤៦

ន សីហមុនី

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ៤៧ ខែសីហា ឆ្នាំ២០២០

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ម៊ិន ឈិន**

ព្រះរាជក្រឹត្យ

ឆស/រកត/០៨២០/ ៩០៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោតាស កម្ពុជ៦ការជរជ្ជបូរណសន្តិ សុតមន្តណ សិរីវិបុណ
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

ត្រេាសព្រះរាជទាន

ទូរ

ក-ត្រៀងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- ឧត្តមសេនីយ៍ត្រី	ត្រិន	សុខចាន់	អត្តលេខ ០៣៧១០៨
២- វរសេនីយ៍ឯក	ណាំ	ពូន	អត្តលេខ ០៧៥៦៦

ខ-ត្រៀងឥស្សរិយយស **មុនីសាភតំណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- ឧត្តមសេនីយ៍ឯក	ណុប	ដារ៉ា	អត្តលេខ ៧៣៤៦៦
២- ឧត្តមសេនីយ៍ឯក	ថោង	សុគន្ធា	អត្តលេខ ០១០៨៩

គ-ត្រៀងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** :

១- ឧត្តមសេនីយ៍ឯក	ជ័យ	បុប្ផា	អត្តលេខ ៥៣៥៧៧
២- វរសេនីយ៍ត្រី	អ៊ុយ	សារីម	អត្តលេខ ៧៣៥២៥

ឃ-ត្រៀងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** :

១- វរសេនីយ៍ឯក	ង៉ែត	មោនីនោ	អត្តលេខ ៧៨០៨៨
២- អនុសេនីយ៍ត្រី	ចាន់	ដារ៉ា	អត្តលេខ ៧៨៤៩១

ង-ត្រៀងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** :

១- អនុសេនីយ៍ឯក	ស៊ុន	សុខពន្ធឹ	អត្តលេខ ៧៨៨១៤
២- វរសេនីយ៍ទោ	សំ	ថុល	អត្តលេខ ៣០៤២៣

ច-ត្រៀងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សប្ចុទ្ធិ** :

- អនុសេនីយ៍ទោ	ជាន	សុខជឿន	អត្តលេខ ៧៧៣៨៨

ឆ-ត្រៀងឥស្សរិយយស **សេនាជ័យសិទ្ធ** :

១- ឧត្តមសេនីយ៍ទោ	ឈីម	សិទ្ធិបុណ្យរិទ្ធ	អត្តលេខ ៨៤៣០១
២- ឧត្តមសេនីយ៍ឯក	ជុន	ថារៀត	អត្តលេខ ៧៩១៦៤

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

៣- ឧត្តមសេនីយ៍ត្រី	ជៀម ចាន់សុខា	អត្តលេខ ០២៤៣៩
៤- វរសេនីយ៍ឯក	សៀក ចន្ធី	អត្តលេខ ០៤៩១៤

លរ៧.២០០៨.៥២៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០២០

ន សីហមុនី

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទិស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ម៉ិន ឈិន

ព្រះរាជក្រឹត្យ

ឆស/រកត/០៨២០/ ៩០៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សហនត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោតាស កម្ពុជ៦ការជរដ្ឋបូរណសន្តិ សុតមន្តណ សិរីវិបុណ
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

ត្រេាសព្រះរាជទាន
នូវ

ក-ត្រៀងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

លោក នៀ សុផន

ខ-ត្រៀងឥស្សរិយយស **មុនីសារាត័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

លោក លី សទ្ធិ

គ-ត្រៀងឥស្សរិយយស **មុនីសារាត័ណ្ឌ** ថ្នាក់ **មហាសេនា** :

១- លោក	ឈឹម	សុគន្ធវារ:	៤- លោក	គង់	កាន្នារ៉ា
២- លោក	ហ៊ុន	ចាន់រិទ្ធ	៥- លោក	ស្រី	ណារ៉ា
៣- លោក	ប្រាក់	កុសល	៦- លោក	យ៉ែម	ប៊ុនឆាត

យ-ត្រៀងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ត** :

១- លោក	សុខ	ឬទ្ធី	៣- លោក	ប៉ៅ	សំអាង
២- លោក	ឡោ	ឆវណ្ណា			

ង-ត្រៀងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** :

១- ឯកឧត្តម	សិត	ខន	៨- លោក	គិន	កោសល្ល
២- លោក	ជីវ	រដ្ឋា	៩- លោក	យង់	គន្ធារិទ្ធ
៣- លោក	ចឹក	លឹម	១០- លោក	ប៉ាវ	សុធីរ
៤- លោក	សំអោ	អង្គារតន៍	១១- លោក	យី	សុងគី
៥- លោក	ហាន	ឌីវីន	១២- លោកស្រី	ហង់	រិន្ធជោទ្ធី
៦- លោក	ទេព	ភិយ្យោរិទ្ធ	១៣- លោក	ហេង	សារិន
៧- លោក	ឡុង	សុវត្ថិ			

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ច-ត្រៀងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សម្ចឆ្ទិ**:

១- ឯកឧត្តម	អ៊ុង	បូរ៉ាត	១០- លោក	តាំង	សុផាណារ័ត្ន
២- ឯកឧត្តម	ពិន	វណ្ណារ៉ូ	១១- លោក	ស	សុភាព
៣- លោក	ប៉ោង	ពីទីន	១២- លោក	រ័ត្ន	សារ៉ា
៤- លោក	អោ	វុត្ថា	១៣- លោក	រ៉ែន	សុភាព
៥- លោក	ថេត	ប្រុស	១៤- លោក	ងួន	ចំន្ទបូភ័ក្ត្រ
៦- លោក	សុក	ថា	១៥- លោក	មៅ	សំរិទ្ធី
៧- លោកស្រី	ពុត	និស្ស៊ីយ	១៦- លោក	ប៉ែង	យីទី
៨- លោក	ថន	ថារិន	១៧- លោក	ឈិន	វ៉ិត
៩- លោកស្រី	ទេព	ស៊ីណាត			

ឧ ស៊ីហមុនី

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០២០

ចានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

យើង

ន៧/រកត/០៨២០/ ៩០៧

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជ៦ការាជ្ជបូរណសន្តិ សុតមន្តលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បន្តាប់

មាត្រា១ : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ឈិន សីសុង** (CHEN SHISONG) ជនជាតិ ចិន សញ្ជាតិ ចិន កើតនៅថ្ងៃទី០៥ ខែមីនា ឆ្នាំ១៩៨៣ នៅខេត្តហ្ជីជៀន សាធារណរដ្ឋប្រជាមានិតចិន។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ឈាម.២០០៨.៩៤៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០២០

ន សីហមុនី

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ចិន ឈិន**

ព្រះរាជក្រឹត្យ

យើង

នស/រកត/០៨២០/ ៩០៨

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ត្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុតមន្ទលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៣២០ / ៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បន្ទាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **លី ថៃសាន្ត** (LEE, TAI-SHAN) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ កើតថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៦២ នៅទីក្រុង New Taipei សាធារណរដ្ឋចិន។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ឯ សីហមុនី

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០២០

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

ន.ស/រកត/០៨២០/ ៧០៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សម្ងានភូមិជាតិសាសនា រក្សាឯកឆ្ត្រិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិត្រ្តាចរាមហាក្សត្រ
ខេមរាជនា សម្ងហោតាស កម្ពុជឯករាជរដ្ឋបូរណាសន្តិ សុគមន្តលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៣២០ / ៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពី ការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **លី ហ្គូឌី** (LEE, KUO-TZU) ជនជាតិចិនតៃវ៉ាន់ សញ្ជាតិចិនតៃវ៉ាន់ កើតថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៨៧ នៅទីក្រុង Taipei សាធារណរដ្ឋចិន។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន **សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ន.ស.២០០៤.៧៣១

ន សីហមុនី

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ *ខែ សីហា ឆ្នាំ ២០២០*

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកអគ្គលេខាធិការដ្ឋានគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/០៨២០/ ៧១០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិត្រ្តាធរាមហាក្សត្រ
ខេមរាជនា សម្ភូហោតាស អម្ពុជឯករាជរដ្ឋបូរណាសន្តិ សុតមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៣២០ / ៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពី ការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ស៊ូ យ៉ុងឈាំង** (SU, YONGQIANG) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៧៥ នៅខេត្ត Fujian សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **ស៊ូ យ៉ុង** (SU YONG)។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០២០

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកអចិន្ត្រៃយ៍គណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ជិន ឈិន**

ព្រះរាជក្រឹត្យ

យើង

នស/រកត/០៨២០/ ៥១១

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុតមន្តណ សិរីវិបុណ
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៣២០ / ៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បន្តាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ហ័ង ជីងភីង** (HUANG, JUNPING) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៩៣ នៅខេត្ត Fujian សាធារណរដ្ឋប្រជាមានិតចិន។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពាក.២០៨.៥៣៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០២០

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/០៨២០/ ៨១៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិង្ករោធរាមហាក្សត្រ
ខេមរាជនា សម្ងហោតាស កម្ពុជឯករាជរដ្ឋបូរណាសន្តិ សុតមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៣២០ / ៨២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពី ការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ឈិន យ៉ាងវ៉ី** (CHEN, YANGWEI) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៨៦ នៅខេត្ត Fujian សាធារណរដ្ឋប្រជាមានិតចិន។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន **សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើ ថ្ងៃ ២០០៥.៨៣៤

ន រ ហ ម

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០២០

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

ព្រះរាជក្រឹត្យ

យើង

នស/រកត/០៨២០/ ៥១៣

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរាវជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុតមន្តណ សិរីវិបុណ
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៣២០ / ៥២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បន្តាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ហេ ប៉ាន** (HE, PAN) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៩០ នៅខេត្ត Sichuan សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **ប៉ាយ ហោអ៊ី** (BAI HAOYU)។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពាក្យ-២០០៥.៥៣៤

ន សីហមុនី

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៤៧ ខែ សីហា ឆ្នាំ ២០២០

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលេបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

ន.ស/រកត/០៨២០/ ៤១៤ យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិឡ្ហាចរាមហាអប្ប្រ
ខេមរាជនា សម្ភូហោតាស អម្ពុជឯករាជរដ្ឋបូរណាសន្តិ សុតមច្ចលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៣២០ / ៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពី ការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

គ្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោកស្រី **វ៉ាងកាម៉ុនមីត តីមថាវ៉ាន់** (WANGAMONMIT PIMPAWAN) ជនជាតិថៃ សញ្ជាតិថៃ កើតថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៩៦ នៅខេត្ត Suphan Buri ព្រះរាជាណាចក្រថៃ ដោយប្តូរឈ្មោះជា **ណាំ លីណេ** (NAM LYNE)។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន **សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ន.ស.រ.២០០៥.៧៣៦

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៧ *ខែ សីហា ឆ្នាំ ២០២០*

បានបម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកអចិន្ត្រៃយ៍នៃគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

យើង

ន្ស/រកត/០៨២០/ ៩១៥

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជ៦ការជរដ្ឋបូរណសន្តិ សុតមន្តណ សិរីវិបុណ
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បន្តាប់

មាត្រា ១ : តម្លើងឋានន្តរស័ក្តិដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ និងនាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ :

ក- ឋានន្តរស័ក្តិឧត្តមសេនីយ៍ឯក

១-	ឧត្តមសេនីយ៍ទោ	**ហេង រស្មី**	អត្តលេខ ០៥១១៨
២-	ឧត្តមសេនីយ៍ទោ	**យុន លីនណេរ៉ូ**	អត្តលេខ ៦៨៤៣៣ ។

ខ- ឋានន្តរស័ក្តិឧត្តមសេនីយ៍ទោ

១-	ឧត្តមសេនីយ៍ត្រី	**កុយ ចិបុល**	អត្តលេខ ០១១៣៩
២-	ឧត្តមសេនីយ៍ត្រី	**រស់ សុចណ្ណា**	អត្តលេខ ០១១៦១
៣-	ឧត្តមសេនីយ៍ត្រី	**ម៉ៅ ចំរើន**	អត្តលេខ ០៣៥៦១

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ឆ្នាះបម៉ោជន៍ខ

៤-	ឧត្តមសេនីយ៍ត្រី	**អាង ឧស្សាហ៍**	អត្តលេខ ០៣៦០៤
៥-	ឧត្តមសេនីយ៍ត្រី	**ឯក ខេន**	អត្តលេខ ០៦៦៩៨
៦-	ឧត្តមសេនីយ៍ត្រី	**ជា សុផល**	អត្តលេខ ០៧៣៧៨
៧-	ឧត្តមសេនីយ៍ត្រី	**ហ៊ី សុគ័ក្ត្រ**	អត្តលេខ ៥៧៤៥៤
៨-	ឧត្តមសេនីយ៍ត្រី	**លីម សំបូរ**	អត្តលេខ ៦៥៣២០
៩-	ឧត្តមសេនីយ៍ត្រី	**ឆណ្ណ ផេង**	អត្តលេខ ៦៦៤៨១ ។

ក- ឋានន្តរស័ក្តិឧត្តមសេនីយ៍ត្រី

១-	វរសេនីយ៍ឯក	**មាស ចាន់ថន**	អត្តលេខ ០១៧១១
២-	វរសេនីយ៍ឯក	**យិន នាយ**	អត្តលេខ ០២២៤៥
៣-	វរសេនីយ៍ឯក	**សូ ម៉ែងលាង**	អត្តលេខ ០៧៧២២
៤-	វរសេនីយ៍ឯក	**ជា សារ៉ុ**	អត្តលេខ ២០៦៥២
៥-	វរសេនីយ៍ឯក	**ម៉ៅ គឹមហាក់**	អត្តលេខ ៣៣៨១៨
៦-	វរសេនីយ៍ឯក	**ចាន់ ពីសាល**	អត្តលេខ ៥៦២៨០
៧-	វរសេនីយ៍ឯក	**លុយ សុន**	អត្តលេខ ៧២៩៣៧
៨-	វរសេនីយ៍ឯក	**ជូ ផល្លីឌីន**	អត្តលេខ ៨៤៣៩២
៩-	វរសេនីយ៍ឯក	**នាយ ពល:**	អត្តលេខ ៨៥០០៩ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួល បន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ចាវណ. ២០០៤. ៩៣៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០២០

ន សីហមុនី

នរោត្តម សីហមុនី

ចានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទិស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ម៉ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/០៨២០/៩១៦

យើង

ព្រះអរុណារព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សម្ងានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិទ្ធាធរមហាក្សត្រ
ខេមរាជនា សម្ងហោតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុតមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **ឈិន ជាងប៉ូ** (CHEN JIANGPO) ជនជាតិ ចិន សញ្ជាតិ ចិន កើតនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៨៩ នៅខេត្តហ៊ូជៀន សាធារណរដ្ឋប្រជាមានិតចិន។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធារ.ជ.២០០៤.៩៣៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០២០

នរោត្តម សីហមុនី

នរោត្តម សីហមុនី

បានឃើញត្រឹមត្រូវតាមច្បាប់ដើម
ទីប្រឹក្សារដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកការងារកិច្ចការគណៈរដ្ឋមន្ត្រី

កិត្តិនីតិសាស្ត្រាចារ្យ ឃិន ឈិន

ព្រះរាជក្រឹត្យ

នស/រកត/០៨២០/ ៩១៧ យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សម្ងានតូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិត្រ្តាធរាមហាក្សត្រ
ខេមរាជនា សម្ងហោតាស កម្ពុជឯករាជរដ្ឋបូរណោសន្តិ សុតមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មជូនលោក **ឈិន ជានហ៊ុយ** (CHEN JIANHUI) ជនជាតិ ចិន សញ្ជាតិ ចិន កើតនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៨៩ នៅខេត្តហ្ស៊ូជៀន សាធារណរដ្ឋប្រជាមានិតចិន។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០២០

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
នាយកដ្ឋានរដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកនិស្សិតការគណៈរដ្ឋមន្ត្រី

កិត្តិនីតិសាស្ត្រាចារ្យ ម៉ិន ឈិន

ព្រះរាជក្រឹត្យ

ន‌ស/រ‌កត/០៨២០/ ៩១៨ យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា អ្នតឧត្តិយា ខេមរាជ្ជរាស្ត្រ ពុទ្ធិង្ករោធរាមហាក្សត្រ
ខេមរាជនា សម្ងហោតាស អង្គុជឯករាជរដ្ឋបូរណសន្តិ សុគមន្តលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៨ / ៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៣២០ / ៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពី ការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៦១៨ / ០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

គ្រោស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **យ៉ាវ ជាអ៊ី** (YAO, JIAYI) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៦៩ នៅខេត្ត Fujian សាធារណរដ្ឋប្រជាមានិតចិន។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ន‌ស.ព្រ.ប.ក្រ.៤៨០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០២០

ន‌ស‌ហ‌

នរោត្តម សីហមុនី

បានជម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកអចិន្ត្រៃយ៍ក្នុងការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

ព្រះរាជក្រឹត្យ

នស/រកត/០៨២០/ ៩១៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)

ត្រាស់បង្គាប់

ផ្តល់គោរមងារ :

លោក **ហោ សំណាង**

ជា

ឧកញ៉ា

៣១៣ស.២០០៤-៩៤១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០២០

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ១២៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការរៀបចំនិងការប្រព្រឹត្តទៅនៃរាជបណ្ឌិត្យសភាកម្ពុជា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពី ការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពី ការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០១៥ ស្តីពី លក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៩/១៩៦២ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៤/៤៣៦ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៤ ស្តីពីការបង្កើតឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៧/៦៤១ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៧ ស្តីពីការផ្ទេរក្រុមប្រឹក្សាជាតិភាសាខ្មែរឱ្យស្ថិតនៅក្រោមសមត្ថកិច្ច និងការទទួលខុសត្រូវរបស់រាជបណ្ឌិត្យសភាកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៧/៥៩២ ចុះថ្ងៃទី១ ខែសីហា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការបង្កើតលេខាធិការដ្ឋានរបស់ក្រុមបណ្ឌិតសភាចារ្យនៃរាជបណ្ឌិត្យសភាកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីនិងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា១ .-

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃរាជបណ្ឌិត្យសភាកម្ពុជា (**រ.ប.ស.ក.**)។

ជំពូកទី២

រចនាសម្ព័ន្ធ

មាត្រា២ .-

រ.ប.ស.ក.មានរចនាសម្ព័ន្ធដូចខាងក្រោម៖

១-អគ្គលេខាធិការដ្ឋាន។

២-វិទ្យាស្ថានរួមមាន៖

- វិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ
- វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម
- វិទ្យាស្ថានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា
- វិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម
- វិទ្យាស្ថានភាសាជាតិ
- វិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃកម្ពុជា
- វិទ្យាស្ថានសិក្សាចិន។

៣-អង្គភាពឧបសម្ព័ន្ធ

- ក្រុមប្រឹក្សាជាតិភាសាខ្មែរ
- ឧទ្យានរាជបណ្ឌិត្យសភាកម្ពុជា តេជោសែន ឫស្សីត្រឹប។

៤-អង្គភាពសវនកម្មផ្ទៃក្នុង។

៥-លេខាធិការដ្ឋានក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ។

វិទ្យាស្ថានចំណុះ **រ.ប.ស.ក**. មានថ្នាក់ស្មើអគ្គនាយកដ្ឋាន។

មជ្ឈមណ្ឌលចំណុះអគ្គលេខាធិការដ្ឋាននៃ**រ.ប.ស.ក**. មានថ្នាក់ស្មើនាយកដ្ឋាន។

រាជបណ្ឌិត្យសភាកម្ពុជាអាចបង្កើតវិទ្យាស្ថានឬអង្គភាពឧបសម្ព័ន្ធដទៃទៀតដោយអនុក្រឹត្យ តាមការចាំបាច់។

រ.ប.ស.ក. អាចមានទីប្រឹក្សាឬជំនួយការមួយចំនួនតាមការចាំបាច់។

រាជបណ្ឌិត្យសភាកម្ពុជាមានរូបសញ្ញានិងត្រាដោយឡែករបស់ខ្លួន។

មាត្រា៣ .-

អគ្គលេខាធិការដ្ឋានដឹកនាំដោយអគ្គលេខាធិការ១(មួយ)រូប ត្រូវមានសញ្ញាបត្របណ្ឌិត និងមានអគ្គលេខាធិការរងមួយចំនួនជាជំនួយការ ស្របតាមបទប្បញ្ញត្តិជាធរមាននិងមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ។ អគ្គលេខាធិការនិងអគ្គលេខាធិការរងជាមន្ត្រីស្ថិតក្នុងក្របខ័ណ្ឌមុខងារសាធារណៈត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

វិទ្យាស្ថានដឹកនាំដោយប្រធាន១(មួយ)រូប ត្រូវមានសញ្ញាបត្របណ្ឌិត និងត្រូវតែងតាំងដោយព្រះរាជក្រឹត្យ និងមានអនុប្រធានមួយចំនួនជាជំនួយការ ស្របតាមបទប្បញ្ញត្តិជាធរមាននិងមានសញ្ញាបត្របណ្ឌិតនិងត្រូវតែងតាំងដោយអនុក្រឹត្យ។ ប្រធាននិងអនុប្រធានត្រូវស្ថិតក្នុងក្របខ័ណ្ឌមុខងារសាធារណៈ។ វិទ្យាស្ថានីមួយៗមានសិទ្ធិប្រើប្រាស់ត្រានិងរូបសញ្ញាដោយឡែករបស់ខ្លួនសម្រាប់បំពេញការកិច្ច។

នាយកដ្ឋាននីមួយៗដឹកនាំដោយប្រធាន១(មួយ)រូប និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ស្របតាមបទប្បញ្ញត្តិជាធរមាន។

មជ្ឈមណ្ឌលដឹកនាំដោយប្រធាន១(មួយ)រូប មានឋានៈស្មើប្រធាននាយកដ្ឋាន និងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ស្របតាមបទប្បញ្ញត្តិជាធរមាន ដែលមានឋានៈស្មើអនុប្រធាននាយកដ្ឋាន។

ការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យចំណុះនាយកដ្ឋាននិងមជ្ឈមណ្ឌលចំណុះអគ្គលេខាធិការដ្ឋាននៃ**រ.ប.ស.ក**. ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

រចនាសម្ព័ន្ធគ្រប់គ្រងរបស់**រ.ប.ស.ក**.ជាឧបសម្ព័ន្ធ១នៃអនុក្រឹត្យនេះ។

ជំពូកទី៣
អគ្គលេខាធិការដ្ឋាននៃ**រ.ប.ស.ក**.

មាត្រា៤ .-

អគ្គលេខាធិការដ្ឋាននៃ**រ.ប.ស.ក**. មានភារកិច្ចដូចខាងក្រោម៖

- ទទួលកម្មវិធីការងារពីប្រធាន**រ.ប.ស.ក**.ដើម្បីដាក់ជូនអង្គភាពក្រោមឱវាទអនុវត្ត
- ទទួលសំណើពីអង្គភាពក្រោមឱវាទ ដើម្បីដាក់ជូនប្រធាន**រ.ប.ស.ក**. ពិនិត្យនិងសម្រេច
- ដឹកនាំនិងគ្រប់គ្រងការងាររដ្ឋបាលនិងហិរញ្ញវត្ថុនៃ**រ.ប.ស.ក**.
- ដឹកនាំនិងគ្រប់គ្រងការងារបណ្តុះបណ្តាលនិងស្រាវជ្រាវនៃ**រ.ប.ស.ក**.

- ដឹកនាំនិងគ្រប់គ្រងការងារបោះពុម្ពផ្សាយនិងបណ្ណាល័យនៃ**រ.ប.ស.ភ**.
- ដឹកនាំនិងគ្រប់គ្រងការងារទំនាក់ទំនងសាធារណៈនៃ**រ.ប.ស.ភ**.
- ដឹកនាំនិងគ្រប់គ្រងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ ការងារបណ្តុះបណ្តាលភាសាបរទេស និងការងារបកប្រែឯកសារ
- អនុវត្តការកិច្ចផ្សេងៗទៀតដែលប្រធាន**រ.ប.ស.ភ**.ប្រគល់ជូន។

មាត្រា៥ .-

អគ្គលេខាធិការដ្ឋាននៃ**រ.ប.ស.ភ**.មាននាយកដ្ឋានជំនាញចំនួន៣(បី) និងមជ្ឈមណ្ឌលចំនួន១(មួយ) ដែលជាសេនាធិការដូចខាងក្រោម៖

- នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- នាយកដ្ឋានបោះពុម្ពផ្សាយនិងបណ្ណាល័យ
- នាយកដ្ឋានទំនាក់ទំនងសាធារណៈនិងពិធីការ
- មជ្ឈមណ្ឌលបណ្តុះបណ្តាលនិងស្រាវជ្រាវ។

រចនាសម្ព័ន្ធគ្រប់គ្រងនៃអគ្គលេខាធិការដ្ឋាននៃ**រ.ប.ស.ភ**.ជាឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ។

មាត្រា៦ .-

នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុមានភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងកិច្ចការរដ្ឋបាលនិងបុគ្គលិក
- រៀបចំផែនការការងាររបស់នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុនិងរបស់**រ.ប.ស.ភ**.
- ផ្គត់ផ្គង់និងគ្រប់គ្រងរាល់សម្ភារៈបរិក្ខារ
- អនុវត្តការងារគ្រប់គ្រងគណនេយ្យនិងហិរញ្ញវត្ថុ
- រៀបចំនិងគ្រប់គ្រងផែនការថវិកា
- រៀបចំបូកសរុបរបាយការណ៍ការងារប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំរបស់នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុនិងរបស់**រ.ប.ស.ភ**.
- សហការនិងសម្របសម្រួលជាមួយអង្គភាពពាក់ព័ន្ធក្នុងការរៀបចំផែនការសេកម្មភាពនិងផែនការយុទ្ធសាស្ត្ររបស់**រ.ប.ស.ភ**.
- អនុវត្តការកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការ**រ.ប.ស.ភ**.ប្រគល់ជូន។

មាត្រា៧ .-

នាយកដ្ឋានបោះពុម្ពផ្សាយនិងបណ្ណាល័យមានភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងការងារបោះពុម្ពនិងចែកផ្សាយ
- គ្រប់គ្រងការងារបណ្ណាល័យនិងបណ្ណាល័យអេឡិចត្រូនិក
- ប្រមូល តម្កល់ គ្រប់គ្រង និងតាំងបង្ហាញស្នាដៃស្រាវជ្រាវ
- ប្រមូល តម្កល់ និងគ្រប់គ្រងនិក្ខេបបទ
- រៀបចំនិងចេញផ្សាយទស្សនាវដ្តីស្រាវជ្រាវ
- អនុវត្តការកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការ**រ.ប.ស.ភ**.ប្រគល់ជូន។

មាត្រា៨ .-

នាយកដ្ឋានទំនាក់ទំនងសាធារណៈនិងពិធីការមានភារកិច្ចដូចខាងក្រោម៖

- ទទួលបន្ទុកការងារទំនាក់ទំនងសាធារណៈនិងផ្សព្វផ្សាយព័ត៌មានរបស់**រ.ប.ស.ក**.
- រៀបចំនិងសម្របសម្រួលកិច្ចការពិធីការរបស់**រ.ប.ស.ក**.
- រៀបចំទីកន្លែងប្រជុំនិងពិធីផ្សេងៗរបស់**រ.ប.ស.ក**.
- រៀបចំឯកសារ លិខិតជូនពរ លិខិតថ្លែងអំណរគុណ និងសាររំលែកទុក្ខផ្សេងៗ ក្នុងនាម **រ.ប.ស.ក**.
- រៀបចំនិងសម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិនិងអន្តរជាតិ
- គ្រប់គ្រងរាល់ឯកសារសហប្រតិបត្តិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការ**រ.ប.ស.ក**.ប្រគល់ជូន។

មាត្រា៩ .-

មជ្ឈមណ្ឌលបណ្តុះបណ្តាលនិងស្រាវជ្រាវមានភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងការបណ្តុះបណ្តាលផ្នែកឧត្តមសិក្សានិងក្រោយឧត្តមសិក្សា
- គ្រប់គ្រងការបណ្តុះបណ្តាលផ្នែកបច្ចេកទេសនិងវិជ្ជាជីវៈ
- គ្រប់គ្រងការបណ្តុះបណ្តាលភាសាបរទេស
- សម្របសម្រួលការស្រាវជ្រាវនិងគ្រប់គ្រងលទ្ធផលស្រាវជ្រាវ
- សហការនិងចាត់ចែងការបកប្រែឯកសារសំខាន់ៗ ពីភាសាបរទេសមកភាសាខ្មែរ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការ**រ.ប.ស.ក**.ប្រគល់ជូន។

ជំពូកទី៤
វិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ

មាត្រា១០ .-

វិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈមានភារកិច្ចដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវ និងផ្សព្វផ្សាយនូវរបកគំហើញលទ្ធផលស្រាវជ្រាវថ្មីៗ អំពីវិស័យវប្បធម៌និងសិល្បៈ នូវស្នាដៃដំនាញហត្ថកម្មនិងបញ្ញាពលកម្ម ដែលកើតចេញពីភាពប៉ិនប្រសប់នៃប្រាជ្ញាល្អប្លែករបស់មនុស្ស ប្រកបដោយគំនិតច្នៃប្រឌិតនិងសោភ័ណភាព
- រៀបចំវេទិកាវិទ្យាសាស្ត្រនានា ដែលពាក់ព័ន្ធនឹងវិស័យវប្បធម៌និងសិល្បៈ
- ប្រមូល ចងក្រង បោះពុម្ពផ្សាយ និងតម្កល់ឯកសារនិងស្នាដៃស្រាវជ្រាវនានាពាក់ព័ន្ធនឹងវិស័យវប្បធម៌និងសិល្បៈ
- ធ្វើកិច្ចសហប្រតិបត្តិការនិងសម្របសម្រួលការសិក្សាស្រាវជ្រាវជាមួយក្រសួង ស្ថាប័ន អង្គការជាតិ និងអន្តរជាតិ ព្រមទាំងដៃគូអភិវឌ្ឍនានាដែលមានឧបនិស្ស័យដូចគ្នា
- អភិវឌ្ឍសមត្ថភាពមន្ត្រីឱ្យកាន់តែប្រសើរឡើងនូវវិធីសាស្ត្រស្រាវជ្រាវលើវិស័យវប្បធម៌និងសិល្បៈស្របតាមបច្ចេកវិទ្យាទំនើប
- គ្រប់គ្រងការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុរបស់វិទ្យាស្ថាន
- រៀបចំផែនការរបស់វិទ្យាស្ថាន
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាន**រ.ប.ស.ក**.ប្រគល់ជូន។

មាត្រា១១ .-

វិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈមាននាយកដ្ឋានចំនួន៦(ប្រាំមួយ)ដូចខាងក្រោម៖

- នាយកដ្ឋានកិច្ចការទូទៅ
- នាយកដ្ឋានវប្បធម៌វិទ្យា
- នាយកដ្ឋានបុរាណវត្ថុវិទ្យា
- នាយកដ្ឋានសិល្បៈទស្សនីយភាព
- នាយកដ្ឋានសិល្បៈនិងឥស្សរិយយស
- នាយកដ្ឋានស្ថាបត្យកម្ម។

រចនាសម្ព័ន្ធគ្រប់គ្រងនៃវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈជាឧបសម្ព័ន្ធ៣នៃអនុក្រឹត្យនេះ។

មាត្រា១២ .-

នាយកដ្ឋានកិច្ចការទូទៅមានភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងការងាររដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុរបស់វិទ្យាស្ថាន
- សហការជាមួយនាយកដ្ឋានពាក់ព័ន្ធក្នុងការរៀបចំផែនការរបស់វិទ្យាស្ថាន
- រៀបចំកម្មវិធីការងារប្រចាំថ្ងៃនិងប្រចាំសប្តាហ៍ជូនប្រធានវិទ្យាស្ថាន
- តាមដាននិងសម្របសម្រួលការអនុវត្តការងាររបស់នាយកដ្ឋានជំនាញនានារបស់វិទ្យាស្ថាន
- រាយការណ៍ព័ត៌មានដែលពាក់ព័ន្ធនឹងវិទ្យាស្ថានជូនថ្នាក់ដឹកនាំវិទ្យាស្ថាន
- សម្របសម្រួលរាល់សកម្មភាពរដ្ឋបាលរបស់វិទ្យាស្ថានជាមួយ**រ.ប.ស.ក**.និងក្រសួង ស្ថាប័នពាក់ព័ន្ធ
- គ្រប់គ្រងសារពើភណ្ឌក្នុងវិទ្យាស្ថាន
- រៀបចំនិងបូកសរុបរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំរបស់វិទ្យាស្ថាន
- សហការជាមួយនាយកដ្ឋានពាក់ព័ន្ធក្នុងការអភិវឌ្ឍសមត្ថភាពធនធានមនុស្សរបស់វិទ្យាស្ថាន ការបោះពុម្ពផ្សាយ ការងារព័ត៌មាន ការរៀបចំវេទិកាវិទ្យាសាស្ត្រនានា ការតម្កល់ឯកសារ និងកិច្ចការបណ្ណាល័យរបស់វិទ្យាស្ថាន
- រៀបចំនិងទទួលបដិសណ្ឋារកិច្ចភ្ញៀវជាតិនិងអន្តរជាតិ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានវិទ្យាស្ថានប្រគល់ជូន។

មាត្រា១៣ .-

នាយកដ្ឋានវប្បធម៌វិទ្យាមានភារកិច្ចដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវ ចងក្រង និងផ្សព្វផ្សាយអំពីចំណេះដឹងវប្បធម៌ ខាងជំនឿ ទំនៀមទម្លាប់ប្រពៃណីជាតិ និងពិធីបុណ្យផ្សេងៗ
- សិក្សាពីវប្បធម៌បរទេសដែលស្ថិតនៅលាយឡំជាមួយវប្បធម៌ខ្មែរ
